សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា

# KhmerPost USA

Free Copies
Email:Khmerpostusa@gmail.com
www.khmerpostusa.com

Vol. 17. Issue 378, December 30, 2025 | Direct: 978-656-8141
Lowell - Lynn - Revere - MA * Providence - Cranston - RI



# វីរៈកងទ័ព១៨រូបរបស់កម្ពុជា មិនត្រូវបានភាគីថៃ ដោះលែងនោះទេ ក្រោយបទឈប់បាញ់ រយៈពេល៧២ម៉ោងបានផុតហើយ

(ភ្នំពេញ)៖ វីរៈកងទ័ព១៨រូបរបស់កម្ពុជា មិនត្រូវបានភាគីយោធាថៃ ដោះលែងនោះទេ ក្រោយកិច្ចព្រមព្រៀងបទឈប់បាញ់រយៈពេល៧២ម៉ោង បានផុតហើយ នៅម៉ោង១២៖០០នាទីថ្ងៃត្រង់ទី៣០ ខែធ្នូ ឆ្នាំ២០២៥នេះ។

## ក្រោយបទឈប់បាញ់ចូលជាស្ថាពរ មិនឮសម្លេងគ្រាប់ទៀតទេ ពលរដ្ឋភៀសសឹកតាមព្រំដែនសាទរ

(បន្ទាយមានជ័យ)៖ បន្ទាប់ពីកិច្ចព្រមព្រៀងនៃបទឈប់បាញ់ជាបន្ទាន់មួយត្រូវបានអនុវត្តន៍ចាប់ពីវេលាម៉ោង១២ថ្ងៃត្រង់ថ្ងៃទី២៧ខែធ្នូឆ្នាំ២០២៥នេះ សំឡេងអាវុធតូចធំតាមសមរភូមិទល់ដែនកម្ពុជា-ថៃ មិនមានឮទៀតនោះឡើយរហូតមកដល់ព្រលប់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥នេះ។

រយៈពេលប្រមាណជា២០ថ្ងៃកន្លងមកនេះ ទល់ដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ

តទៅទំព័រទី២២



ROSA & TAING LAW, LLC



Attorney Francisco J. Rosa
មេធាវី ហ្វ្រានស៊ីសស្កូ ជេ. រ៉ូសា

Attorney Andrew 'Bunna' Taing
មេធាវី អេនឌ្រូ ប៊ុណ្ណា តាំង

Concentrated in
Auto Accident
Personal Injury
Real Astate Closing
Immigration
Divorces
Child Custody
Bankuptcy

ជំនាញខាងផ្នែក៖
គ្រោះថ្នាក់រថយន្តគ្រប់ប្រភេទ
ការងាររបួសផ្ទាល់ខ្លួន
ការកាត់ឈ្មោះប្តូរផ្ទះ
អន្តោប្រវេសន៍
ការលែងលះ
ការគ្រប់គ្រងថែរក្សាកូន
ក្ស័យធន

Main Office / Mailing Address
1550 Middlesex Street
Lowell, MA 01851

Revere Office
385 Broadway, Suite 305
Revere, MA 02151

978-458-0934 • at@rosataing.com

# Lowell, Massachusetts, Becomes First U.S. City Named a UNESCO Learning City

LOWELL, Mass., December 16, 2025 — The City of Lowell is proud to announce that Lowell has been officially designated a United Nations Educational, Scientific, and Cultural Organization (UNESCO) Learning City, becoming the first municipality in the United States to earn this international recognition. UNESCO announced the 72 newest members to its Global Network of Learning Cities on December 4, 2025, highlighting cities around the world that demonstrate an exceptional commitment to lifelong learning for residents of all ages.

UNESCO Learning Cities promote learning everywhere: in schools and universities, workplaces, libraries, homes, neighborhoods, and public spaces. They provide opportunities for residents to build new skills, adapt to changing industries, strengthen digital literacy, explore creative expression, and engage more deeply in civic life.

The UNESCO Global Network of Learning Cities now includes 425 cities from 91 countries, collectively supporting nearly 500 million residents. Lowell joins this global community as the first American city to earn the designation — reflecting decades of investment in education, workforce development, cultural enrichment, and access to learning at every stage of life.

Lowell's selection reflects the city's 200-year legacy as a place where learning, innovation, and cultural exchange have always been central to community life. From its earliest days, the city learned to harness waterpower to build the first industrial city in the United States, creating new technologies and economic models that reshaped the nation. At the same time, Lowell learned to attract and educate a new kind of



Lowell's delegations at the Palais des Nations, Lowell was celebrated as the First U.S. Frontrunner City — a pioneering model of how community expectations and local innovation can advance the UN's Sustainable Development Goals (SDGs), aligned with global priorities to drive worldwide transformation. Photo September, 2025

workforce — young women who used their free time to attend lectures, publish journals, and develop rich intellectual networks that remain an early example of organized adult education in America.

The city established Lowell High School in 1831, the first co-ed and first integrated high school in the nation, reflecting a belief that education must be accessible to all. That same ethic of shared learning supported civic innovation in the 1970s, when leaders such as Paul Tsongas drew on new federal tools to create Lowell National Historical Park, enabling residents and visitors alike to learn from the city's industrial, labor, and cultural history. Decades of collaboration among artists, educators, businesses, and community organizations have since helped reinvent Lowell as a cultural and creative hub.

Today, a student can go from Pre-K to PhD without ever leaving the city. Partnerships among the City of Lowell, Lowell Public Schools, Middlesex Community College, UMass Lowell, and dozens of nonprofit organizations ensure that residents of every age have opportunities to develop new skills, explore the arts, strengthen digital literacy, and engage in civic life.

"In Lowell, you can begin your education in our early childhood programs and continue all the way through a doctoral degree — and that continuity is something very few cities can claim," said City Manager Thomas A. Golden, Jr. "This UNESCO designation recognizes the strength of that ecosystem and the commitment of our educators, community partners, cultural organizations, and workforce leaders to ensure learning is accessible to every resident. Being a UNESCO Learning City is an extraordinary honor."

Mayor Daniel P. Rourke emphasized how deeply rooted the value of learning is in the city's identity. "Lowell has always been a city of opportunity. Generations of families have come here because this is a place where education opens doors. To be recognized by UNESCO as a Learning City honors our past and strengthens our future. Whether you're a child entering Pre-K, a new American learning English, a worker learning new skills, or a graduate student pursuing a PhD, Lowell offers pathways for every learner at every stage of life, and that's something we're incredibly proud of."

"Being designated the first UNESCO Learning City in the United States is a major achievement for all of Lowell," said John Wooding, Lowell City of Learning President. "This builds on the legacy of Pat Mogan, and of all the great learning opportunities built into the fabric of the city. Not only will this put Lowell on the world map, but will also provide recognition, access to UNESCO's Global Network of Learning Cities, and all the resources such a network represents. This is a major win for all of the Lowell community, its excellent educational institutions, and for all the organizations in Lowell who see learning in all its forms as critical to making Lowell an internationally known educative city."

As a member of the UNESCO Global Network of Learning Cities, Lowell will collaborate with cities around the world to share innovative practices, develop inclusive learning policies, and create new programs that support education, sustainability, equity, and community wellbeing. For more information, please visit: https://www.uil.unesco.org/en/learning-cities/lowell


LCCPS LOWELL COMMUNITY CHARTER PUBLIC SCHOOL
ទទួលពាក្យចូលរៀន
ឆ្នាំ ២០២៦/២០២៧
98.7%
ក្រុមគ្រួសារនិយាយប្រាប់ថា សាលារៀនធានារៀបចំឱ្យកូនៗ របស់ពួកគេទទួលបាន ជោគជ័យនៅពេលអនាគត់ ។
ហេតុអ្វីបានជ្រើសរើសយើង ?
• គាំទ្រភាសាអង់គ្លេស ELL និងតម្រូវការពិសេស
• កម្មវិធីសិក្សាបន្ថែមពេល
• កម្មវិធីប្រគួតកីឡា
• កម្មវិធីបន្ថែមពហុមុខវិជ្ជា
• កម្មវិធីសិស្សពូកែ និងឆ្លាតវៃ
• កម្មវិធីសិក្សារយៈពេលវែង ពេលថ្ងៃ និងឆ្នាំ
• និង កម្មវិធីជាច្រើនបន្ថែមទៀត !
Panthers
ដំណើរការទទួលពាក្យចូលរៀនៈ
• ចូលគេហទំព័ររបស់យើង www.lccps.org
• បំពេញបែបបទដាក់ពាក្យតាមអិនធឺណេត
• ដាក់ពាក្យសុំជាមួយឯកសារដែលចាំបាច់
• ចូលរួមជាមួយដើម្បីទស្សនាសាលារៀន
• ចូលរួមប្រជុំវគ្គផ្សព្វផ្សាយព័ត៌មាន / ការចាប់ឆ្នោត។
ថ្ងៃសំខាន់ ៖
• ថ្ងៃផុតកំណត់ទទួលពាក្យៈ ថ្ងៃទី២៧ ខែកុម្ភ ឆ្នាំ២០២៦
• វគ្គផ្សព្វផ្សាយព័ត៌មានៈ ថ្ងៃអង្គារ ទី៦ខែមករា ថ្ងៃព្រហស្បតិ៍ ទី៥ ខែកុម្ភៈ ឆ្នាំ២០២៦ ពីម៉ោង ៥:៣០ ល្ងាច
• ថ្ងៃចាប់ឆ្នោតៈ ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៦ ម៉ោង ៥:៣០ល្ងាច
ជួបទំនាក់ទំនងយើងតាមរយៈ
978 - 323 - 0800
206 Jackson Street Lowell, MA
www.lccps.org
ភាពជាអ្នកដឹកនាំ | ឧត្តមភាព | ភាពជោគជ័យ | ពហុជាតិសាសន៍

# ប្រមុខការទូតអាស៊ានឯកភាពឱ្យបើកកិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ GBC នៅថ្ងៃទី២៤ ធ្នូ

រដ្ឋមន្ត្រីការបរទេសអាស៊ានឯកភាពឱ្យបើកកិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ (GBC) នៅថ្ងៃទី២៤ ខែធ្នូ ខាងមុខនេះ ក្នុងបំណងពិភាក្សាអំពីការអនុវត្ត និងការផ្ទៀងផ្ទាត់បទឈប់បាញ់ និងដើម្បីស្តារបទឈប់បាញ់ឡើងវិញ រួមទាំងការបញ្ឈប់សកម្មភាពអរិភាពនានាឱ្យបានឆាប់។

ប្រធានអាស៊ាន ចេញសេចក្តីថ្លែងការណ៍ស្តីពីកិច្ចប្រជុំពិសេសរបស់រដ្ឋមន្ត្រីការបរទេសអាស៊ាន នៅថ្ងៃទី២២ ធ្នូ នេះថា កិច្ចប្រជុំនេះបានសម្រេចលើលក្ខខណ្ឌ ១០ចំណុច ក្នុងនោះក៏បានរំឭកឡើងវិញអំពីកិច្ចព្រមព្រៀងបទឈប់បាញ់កាលពីថ្ងៃទី២៨ ខែកក្កដា រួមមានការសម្រេចរបស់កិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅពិសេស (GBC) ថ្ងៃទី៧ ខែសីហា និងសេចក្តីថ្លែងការណ៍រួមក្រុងកូឡាឡាំពួរ ផងដែរ ដើម្បីជំរុញឱ្យកម្ពុជា និងថៃ អនុវត្តវាឱ្យបានពេញលេញនិងមានប្រសិទ្ធភាព។

ប្រភពដដែល អះអាងថា កិច្ចប្រជុំនេះក៏បានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរួមគ្នាក្នុងការចៀសវាងការគំរាមកំហែង ឬការប្រើប្រាស់កម្លាំងដែលត្រូវដោះស្រាយជម្លោះដោយសន្តិភាព និងគោរពច្បាប់ព្រំដែនអន្តរជាតិ និងច្បាប់អន្តរជាតិ ដោយផ្អែកលើការគោរពគ្នាទៅវិញទៅមកចំពោះឯករាជ្យអធិបតេយ្យភាព បូរណភាពទឹកដី ស្របតាមធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ាន។

សេចក្តីថ្លែងការណ៍នេះ បញ្ជាក់ថា កិច្ចប្រជុំនេះបានប្តេជ្ញាចិត្តចំពោះសាមគ្គីភាព និងសាមគ្គីអាស៊ានក្នុងការធានាសន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាពក្នុងតំបន់ ស្របតាមធម្មនុញ្ញរបស់អាស៊ាន។

កិច្ចប្រជុំនេះ ធ្វើឡើងស្របពេលដែលសង្គ្រាមកម្ពុជា-ថៃ កំពុងផ្ទុះឡើងវិញជាលើកទីពីរ និងបានអូសបន្លាយអស់រយៈពេលជាង ១០ថ្ងៃមកហើយ។

កាសែតថៃ The Nation ស្រង់សម្តីរដ្ឋមន្ត្រីការបរទេសថៃ លោក ស៊ីហាសាក់ ភួងកេតកែវ (Sihasak Phuang-ketkeow) នៅថ្ងៃទី២២ ធ្នូ នេះថា ដើម្បីអនុវត្តកិច្ចព្រមព្រៀងក្រុងកូឡាឡាំពួរឱ្យមានប្រសិទ្ធភាព ថៃបានស្នើលក្ខខណ្ឌចំនួន៣ ក្នុងនោះរួមមាន កម្ពុជាត្រូវតែប្រកាសបទឈប់បាញ់ជាសាធារណៈ បទឈប់បាញ់ត្រូវតែអនុវត្ត និងរក្សាឱ្យបាន ចុងក្រោយកម្ពុជាត្រូវតែសហការប្រកបដោយភាពស្មោះត្រង់ក្នុងកិច្ចខិតខំប្រឹងប្រែងដោះមីន។

រដ្ឋមន្ត្រីការបរទេសថៃ រូបនេះបញ្ជាក់ថាដើម្បីអនុវត្តសេចក្តីថ្លែងការណ៍រួមក្រុងកូឡាឡាំពួរ ឱ្យមានប្រសិទ្ធភាព កម្ពុជាត្រូវតែឈប់បាញ់ជាមុន ព្រោះកម្ពុជាត្រូវចាត់ទុកជាអ្នកចាប់ផ្តើមសង្គ្រាមជាមួយថៃ ក្នុងពេលនេះ។




កិច្ចប្រជុំពិសេសរបស់រដ្ឋមន្ត្រីការបរទេសអាស៊ាន នាទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥។

យ៉ាងណាក៏ដោយប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា លោកឆាំង យុលើកឡើងនៅថ្ងៃទី២២ ធ្នូ នេះដែរថា ការទាមទារនូវលក្ខខណ្ឌទាំង ៣ចំណុចរបស់ថៃគ្មាននៅក្នុងមូលដ្ឋានច្បាប់អន្តរជាតិទេ ខណៈថៃក៏មិនអាចស្វែងរកការគាំទ្រពីអន្តរជាតិបានដែរចំពោះលក្ខខណ្ឌទាំងបីនេះ។

លោកឆាំង យុ ព្រមានថា សង្គ្រាមកម្ពុជា-ថៃ នាពេលនេះ មិនត្រឹមតែជាបញ្ហាតំបន់ព្រំដែនរវាងប្រទេសទាំងពីរទេ ប៉ុន្តែវាក៏នឹងអាចជះឥទ្ធិពលដល់តំបន់ទាំងមូល ហើយក៏ប្រហែលជាជះឥទ្ធិពលទៅដល់ពិភពលោកទាំងមូលថែមទៀត ដូច្នេះជម្លោះនេះគឺត្រូវតែបញ្ចប់ តែក៏មិនមែនបញ្ចប់ដោយលក្ខខណ្ឌជ្រុលនិយមដែលរដ្ឋាភិបាលថៃ បានស្នើឡើងនេះដែរ។

ជុំវិញបញ្ហានេះ ទីភ្នាក់ងារសារព័ត៌មានអន្តរជាតិ រ៉យទ័រ (Reuter) បានរាយការណ៍នៅថ្ងៃទី២២ ធ្នូ នេះថា នាយករដ្ឋមន្ត្រីម៉ាឡេស៊ី លោក អាន់វ៉ា អ៊ីប្រាហ៊ីម និងជាប្រធានអាស៊ាន បានថ្លែងកាលពីថ្ងៃទី២១ ខែធ្នូ ថា លោកបានសង្កត់ធ្ងន់លើសារសំខាន់សម្រាប់ប្រទេសកម្ពុជា និងថៃ ក្នុងការលើកកម្ពស់ស្មារតីនៃការសន្ទនា ដើម្បីបញ្ចប់ភាពតានតឹង និងរក្សាសន្តិភាព និងស្ថិរភាពនៅក្នុងតំបន់។

លោក អាន់វ៉ា អ៊ីប្រាហ៊ីម បានបញ្ជាក់ថា ក្រុមអ្នកសង្កេតការណ៍អាស៊ាននឹងបង្ហាញការរកឃើញដល់រដ្ឋមន្ត្រីការបរទេសពីការសង្កេតនៅមូលដ្ឋាន និងទិន្នន័យដែលចាប់យកដោយបច្ចេកវិទ្យាត្រួតពិនិត្យផ្កាយរណបដែលផ្តល់ដោយសហរដ្ឋអាមេរិក។

ជុំវិញបញ្ហានេះ អ្នកជំនាញផ្នែកច្បាប់ លោកមេធាវី សុក សំអឿន បានសរសេរលើគណនីហ្វេសប៊ុករបស់ខ្លួននៅថ្ងៃទី២២ ធ្នូ នេះថា សង្គ្រាមកម្ពុជា-ថៃ ដែលកើតឡើង គឺដោយសារការវាយប្រហារពីសំណាក់យោធាថៃ មកលើដែនអធិបតេយ្យកម្ពុជាមុន ខណៈយន្តការដោះស្រាយអន្តរជាតិ គឺត្រូវធ្វើឡើងដោយអង្គការតំបន់ គឺអាស៊ាន និងអង្គការសហប្រជាជាតិ។

អ្នកជំនាញផ្នែកច្បាប់កម្ពុជារូបនេះបញ្ជាក់ថា សង្គ្រាមកម្ពុជា-ថៃ គឺមានតែខ្លួនទីពឹងខ្លួនជាងមុនប៉ុណ្ណោះ ទម្រាំមានដំណោះស្រាយដោយអង្គការតំបន់ ព្រោះអាស៊ានមិនមានយន្តការធ្វើអន្តរាគមន៍លើប្រទេសដែលឈ្លានពានប្រទេសមួយទៀតនោះទេ ក្រៅតែពីការសម្របសម្រួលនោះ។

# ចិន និងអាមេរិក រុញថៃ-កម្ពុជា ឱ្យបញ្ឈប់ការវាយប្រយុទ្ធគ្នាមុនជំនួបប្រមុខការទូតអាស៊ាននៅថ្ងៃទី២២ ធ្នូ

អ្នកនាំពាក្យក្រសួងការពារជាតិកម្ពុជា បង្ហាញរបាយការណ៍អំពីស្ថានការណ៍សឹកដែលកងទ័ពថៃនៅតែបន្តឈ្លានពានទឹកដីកម្ពុជា នៅយោធភូមិភាគទី៤ និងទី៥។

តាមអ្នកនាំពាក្យក្រសួងការពារជាតិកម្ពុជា អ្នកស្រី ម៉ាលី សុជាតា ស្ថានការណ៍ជួរមុខក្នុងសមរភូមិយោធភូមិភាគទី៥ ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ និងខេត្តពោធិ៍សាត់ កងទ័ពថៃ នៅតែបន្តបាញ់ប្រហារមកកម្ពុជា គិតចាប់ពីម៉ោង ៥ល្ងាចថ្ងៃទី១៨ធ្នូ។ ក្នុងការវាយប្រហារយ៉ាងកំរោលនេះ កងទ័ពថៃ បានប្រើប្រាស់អាវុធធុនធ្ងន់ដូចជា យន្តហោះចម្បាំង F-16 នាវាចម្បាំង កាំភ្លើងធំ ១៥៥មិល្លីម៉ែត្រ ១០៥មិល្លីម៉ែត្រ រថយន្តបាញ់រ៉ុក្កែត DTI-2 ដ្រូនទម្លាក់គ្រាប់បែក និងបាញ់ផ្សែងពុល។




រដ្ឋមន្ត្រីការបរទេសចិន លោក វ៉ាង យី (ឆ្វេង) និងរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក លោក Marco Rubio

អ្នកនាំពាក្យក្រសួងការពារជាតិកម្ពុជា រូបនេះ បានហៅប្រទេសថៃគឺជារដ្ឋដែលបំពានច្បាប់អន្តរជាតិ ជារដ្ឋដែលបំផ្លាញសន្តិភាព និងសន្តិសុខ ប៉ះពាល់ខ្លាំងដល់ស្ថិរភាពតំបន់។

គិតត្រឹមថ្ងៃសុក្រ ទី១៩ ខែធ្នូ ឆ្នាំ ២០២៥ នេះ សង្គ្រាមថៃ ឈ្លានពានកម្ពុជា ចូលដល់ថ្ងៃទី១៣ ហើយ។

ជុំវិញស្ថានការណ៍សឹកថៃឈ្លានពាននេះ រដ្ឋមន្ត្រីការបរទេសអាមេរិក លោក Marco Rubio បានទូរសព្ទទៅកាន់សមភាគីថៃ លោក Sihasak Phuangketkeow ដោយបង្ហាញពីការព្រួយបារម្ភរបស់សហរដ្ឋអាមេរិកចំពោះហិង្សាដែលកំពុងបន្តកើតឡើងនៅព្រំដែនជាមួយកម្ពុជា។

អ្នកនាំពាក្យរងការបរទេសអាមេរិក លោក Tommy Pigott បានអះអាងកាលពីថ្ងៃទី១៨ ខែធ្នូ ថា ក្នុងកិច្ចសន្ទនានោះ ប្រមុខការទូតសេតវិមាន បានជំរុញឱ្យកាត់បន្ថយភាពតានតឹងជាបន្ទាន់រវាងប្រទេសទាំងពីរ គឺថៃ និងកម្ពុជា។

តទៅទំព័រទី២១

Mass·ECHOS Massachusetts Economic Conditions & Household Opportunity Survey
Federal Reserve Bank of Boston

បញ្ចេញ
មតិយោបល់
ជាសំឡេង
របស់អ្នក

សូមធ្វើការស្ទង់មតិរបស់ Mass ECHOS ។

ការឆ្លើយតបរបស់អ្នកសំខាន់ណាស់។
ចម្លើយរបស់អ្នកនឹងជួយឱ្យពួកយើងស្វែងយល់បន្ថែមអំពីហិរញ្ញវត្ថុគ្រួសារនៅរដ្ឋ Massachusetts ។

ការសិក្សានេះ ដឹកនាំដោយធនាគារកណ្តាលនៃទីក្រុង Boston ក្នុងភាពជាដៃគូជាមួយមូលនិធិ Boston និងដៃគូរបស់ពួកគេ មានគោលបំណងស្វែងយល់ពីស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារនៅទូទាំងរដ្ឋ Massachusetts ។ ការរកឃើញនឹងជួយជូនដំណឹងអំពីយុទ្ធសាស្ត្រសម្រាប់ឱកាសសេដ្ឋកិច្ចកាន់តែច្រើន។

ការស្ទង់មតិនេះនឹងផ្តោតលើហិរញ្ញវត្ថុគ្រួសារ រួមទាំងទ្រព្យសម្បត្តិ (ដូចជាផ្ទះ) និងបំណុលដូចជាកម្ចីសម្រាប់សិស្ស។ អ្នកនឹងមិនត្រូវបានស្នើសុំលេខគណនី ឬកន្លែងទុកដាក់ប្រាក់កាក់របស់អ្នកនោះទេ ហើយចម្លើយទាំងអស់នឹងត្រូវការទុកជាការសម្ងាត់។ ការចូលរួមរបស់អ្នកនឹងផ្តល់ការយល់ដឹងអំពីរបៀបដែលមនុស្សកំពុងធ្វើនៅ Massachusetts ។ អ្នកចូលរួមនឹងទទួលបាន**កាតអំណោយ $50** ពីក្រុមហ៊ុនស្ទង់មតិជាការថ្លែងអំណរគុណ។

**តើអ្នកទទួលបានការអញ្ជើញជាមួយនឹងនិមិត្តសញ្ញា Mass ECHOS ទេ?**
បើដូច្នេះមែន សូមអនុវត្តជំហានទាំងបីនេះ ដើម្បីចូលរួមក្នុងការស្ទង់មតិ៖

1. ធ្វើការស្ទង់មតិតាមអ៊ីនធឺណិតឬនៅលើក្រដាសប្រសិនបើអ្នកចង់
2. ដាក់ស្នើចម្លើយរបស់អ្នក
3. រកមើលកាតអំណោយ Visa ចំនួន $50 របស់អ្នកពីក្រុមហ៊ុនស្ទង់មតិនៅក្នុងសំបុត្រ

# មន្ត្រីបក្សប្រឆាំងស្នើឱ្យអឺរ៉ុប និងអាមេរិក ដាក់ពង្រាយផ្កាយរណប តាមដានភាគីណាបង្កជម្លោះឈ្លានពានទឹកដីពិតប្រាកដ

មន្ត្រីជាន់ខ្ពស់បក្សប្រឆាំង ស្នើឱ្យសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក ដាក់ពង្រាយផ្កាយរណបដើម្បីតាមដានផ្ដិតយកភស្តុតាងភាគីដែលឈ្លានពានទឹកដី ព្រោះភាគីថៃ តែងតែបង្កើតភស្តុតាងក្លែងក្លាយដើម្បីលាបពណ៌ និងចោទប្រកាន់កម្ពុជាថាបានឈ្លានពានទឹកដីរបស់ពួកគេរហូតមកនោះ។

លោក មុត ចន្ថា ដែលជាអតីតនាយកខុទ្ទកាល័យប្រធានគណបក្សសង្គ្រោះជាតិ លោក កឹម សុខា សរសេរលើគណនីហ្វេសប៊ុករបស់លោកនៅថ្ងៃទី១៨ ធ្នូ នេះថា ដើម្បីជម្រះការចោទប្រកាន់ឱ្យជ្រះស្រឡះ និងធានាដល់ការអនុវត្តបទឈប់បាញ់ គួរតែបើកឱ្យសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក ដាក់ពង្រាយផ្កាយរណបដើម្បីតាមដានសង្គ្រាមព្រំដែនកម្ពុជា-ថៃ ថាតើភាគីណាជាអ្នកឈ្លានពានភាគីណាឱ្យពិតប្រាកដ។

មន្ត្រីបក្សប្រឆាំងរូបនេះបញ្ជាក់ថាកន្លងមកភាគីថៃ តែងតែបង្កើតភស្តុតាងក្លែងក្លាយដើម្បីលាបពណ៌ និងចោទប្រកាន់កម្ពុជា ថាបានរំលោភបំពានបទឈប់បាញ់ ដាក់មីនថ្មី និងបើកការវាយប្រហារទៅលើភាគីថៃ មុនជាដើមដូច្នេះដើម្បីបញ្ចប់ការចោទប្រកាន់គ្នាទៅវិញទៅមក តើថៃ ហ៊ានទទួលយកការចូលរួមឃ្លាំមើលរបស់សហភាពអឺរ៉ុប ជុំវិញជម្លោះព្រំដែនជាមួយកម្ពុជាក្នុងពេលនេះដែរឬទេ។

ការស្នើនេះ ធ្វើឡើងបន្ទាប់ពីសហភាពអឺរ៉ុប ប្រកាសពីការផ្តល់រូបភាពពីផ្កាយរណបសម្រាប់ការឃ្លាំមើលបទឈប់បាញ់ជុំវិញសង្គ្រាមកម្ពុជា-ថៃ ដែលបានផ្ទុះឡើងជាលើកទី២ នាពេលនេះ។

តំណាងជាន់ខ្ពស់របស់សហភាពអឺរ៉ុប ទទួលបន្ទុកកិច្ចការបរទេស និងគោលនយោបាយសន្តិសុខ និងជាអនុប្រធានគណៈកម្មការអឺរ៉ុប អ្នកស្រី



យន្តហោះចម្បាំង F-16 របស់យោធាថៃ ទម្លាក់គ្រាប់ ២គ្រាប់លើប៉ុស្តិ៍រដ្ឋបាលសង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៥។

Kaja Kallas បានចេញសេចក្តីថ្លែងការណ៍លើបណ្តាញទំនាក់ទំនងសង្គម អិច (X) របស់ខ្លួនកាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ២០២៥ នេះថា សហភាពអឺរ៉ុប អាចផ្តល់ជូននូវរូបភាពពីផ្កាយរណបសម្រាប់ការឃ្លាំមើលបទឈប់បាញ់ជុំវិញជម្លោះព្រំដែនកម្ពុជា-ថៃ ប្រសិនបើប្រទេសទាំងពីរត្រូវការ។

តំណាងជាន់ខ្ពស់របស់សហភាពអឺរ៉ុបរូបនេះ បញ្ជាក់ថា បទឈប់បាញ់ចាំបាច់ត្រូវតែស្តារឡើងវិញជាបន្ទាន់ ព្រោះជម្លោះរវាងប្រទេសកម្ពុជា និងថៃ មិនត្រូវបណ្តោយឱ្យរាលដាលកាន់តែធ្ងន់ធ្ងរឡើយ ខណៈអ្នកស្រីក្នុងនាមជាអនុប្រធានគណៈកម្មការអឺរ៉ុប នឹងបន្តកិច្ចការនេះដើម្បីជួយបញ្ចប់ការកើនឡើងជម្លោះតាមបណ្តោយព្រំដែនរវាងកម្ពុជា-ថៃ នាពេលនេះ។

សង្គ្រាមតាមបណ្តោយព្រំដែនរវាងកម្ពុជា-ថៃ បានឆ្លងចូលដល់ថ្ងៃទី១២ ហើយ ខណៈកម្ពុជា បានអះអាងថា យោធាថៃ បានវាយប្រហារមកលើកម្ពុជាមុន និងបន្តវាយប្រហារចូលជ្រៅក្នុងទឹកដីរបស់ខ្លួនកាន់តែឆ្ងាយពីព្រំដែនជិត ១០០គីឡូម៉ែត្រហើយនាពេលនេះ ប៉ុន្តែខាងភាគីថៃ ក៏បានអះអាងថា ខាងកម្ពុជា គឺជាអ្នកវាយប្រហារលើខ្លួនមុន។

ជុំវិញបញ្ហានេះ រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក នេត្រ ភក្ត្រា នៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០២៥ នេះ អះអាងថា ពេលនេះ ទីភ្នាក់ងារសារព័ត៌មានបរទេសធំៗ រួមមាន CNN, AP និង ទីភ្នាក់ងារសារព័ត៌មានបារាំង AFP ព្រមទាំងបណ្តាញព័ត៌មានជាច្រើនទៀត បាននាំសំឡេងរបស់កម្ពុជា ប្រាប់ពិភពលោកថា យោធាថៃ បានបើកការវាយប្រហារមកលើកម្ពុជា ជុំវិញសង្គ្រាមតាមព្រំដែននាពេលនេះ។

លោក នេត្រ ភក្ត្រា បញ្ជាក់ថា ទីភ្នាក់ងារសារព័ត៌មានអន្តរជាតិ AP ក៏បានចូលរួមនាំការពិតពីកម្ពុជា ប្រាប់ពិភពលោកឱ្យបានដឹងអំពីការទម្លាក់

**តទៅទំព័រទី១៩**



# អ្នកតាមដានស្ថានការណ៍អធិប្បាយថា ថៃវាយប្រហារដោយ ប្រើយន្តហោះចម្បាំងច្រើនប្រភេទដើម្បីបង្ខំខ្មែរឱ្យសុំចរចា

អ្នកឃ្លាំមើលសង្គម លើកឡើងថា ការវាយប្រហារដោយការប្រើយន្តហោះចម្បាំង F-16, T-50 និង Gripen JAS-39 លើទឹកដីប្រទេសកម្ពុជា ក្នុងពេលដែលប្រទេសទាំងពីរត្រៀមកិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅ (GBC) ចរចាឱ្យមានបទឈប់បាញ់ គឺជាល្បិចដែលថៃបានប្រើប្រាស់ក្រោមយុទ្ធសាស្ត្រវាយសម្លុតដើម្បីបង្ខំឱ្យភាគីកម្ពុជា សុំចរចា។

ម្ចាស់គណនីហ្វេសប៊ុកឈ្មោះ ឡាំឡាយ ដែលជាអ្នកតាមដានស្ថានការណ៍កម្ពុជា បានសរសេរលើគណនីហ្វេសប៊ុករបស់ខ្លួនកាលពីយប់ថ្ងៃទី២៤ ធ្នូ នេះថា ការប្រើប្រាស់កម្លាំងទ័ពអាកាសដ៏លើសលប់របស់ថៃ មិនមែនធ្វើឡើងក្នុងគោលបំណងចង់ឈ្នះសង្គ្រាមទាំងស្រុងភ្លាមៗនោះទេ។ លោកថា តាក់ទិចបែបនេះ គឺជារបៀបវាយសម្លុតក្នុងគោលបំណងបង្ខំឱ្យគូបដិបក្ខទៅអង្គុយនៅតុចរចាដែលចាញ់ប្រៀបថៃ ហើយក៏ដើម្បីសម្រេចមហិច្ឆតាឈ្លានពានទៅថ្ងៃមុខដែរ។

ប្រភពដដែលលើកឡើងថា ថៃកំពុងប្រើល្បិចកលធ្វើឱ្យជម្លោះជាមួយកម្ពុជាក្លាយជាជម្លោះនិងការដោះស្រាយជាលក្ខណៈទ្វេភាគី ក្នុងបំណងរុញច្រានតួនាទីជាអាជ្ញាកណ្ដាលរបស់ប្រទេសម៉ាឡេស៊ី ចេញឱ្យផុតពីជម្លោះនេះ ក្នុងគោលដៅឱ្យថៃ អាចឈ្លានពានកម្ពុជាដោយគ្មានការត្រួតពិនិត្យ ឬការសម្របសម្រួលតាមផ្លូវច្បាប់អន្តរជាតិដែលពហុភាគីនិយមគាំទ្រនោះ។

ជាងនេះទៀត ថៃ ក៏មានចេតនារុញកម្ពុជា ឱ្យធ្លាក់ក្នុងអន្ទាក់នៃល្បែងភូមិសាស្ត្រនយោបាយរបស់អំណាចរវាងអាមេរិក និងចិន ដែរ ព្រោះថាក្នុងសង្គ្រាមនេះ បើកម្ពុជា ងាកទៅរកការគាំទ្រពីចិន ខ្លាំងពេក ថៃនឹងប្រើលេសនេះទាញអាមេរិក ឱ្យចូលជម្លោះនេះមកកាន់តែជ្រៅ ដោយប្រើលេសទប់ស្កាត់ឥទ្ធិពលចិន។



យន្តហោះចម្បាំងរបស់ថៃ ទម្លាក់គ្រាប់បែកជាច្រើនកន្លែងលើទឹកដីប្រទេសកម្ពុជា

អ្នកតាមដានស្ថានការណ៍កម្ពុជារូបនេះបញ្ជាក់ថា ប្រសិនបើស្ថានភាពសង្គ្រាមកម្ពុជា-ថៃឈានដល់ដំណាក់កាលនេះ នោះកម្ពុជា នឹងក្លាយជាទីលានប្រជែងឥទ្ធិពលរវាងមហាអំណាចជាមិនខាន ខណៈថៃ ក៏អាចចេញមុខដោយស្របច្បាប់កម្ទេចកម្ពុជា ដោយប្រើលេសបង្ក្រាបឧក្រិដ្ឋកម្មឆបោកតាមអនឡាញក្រោមល្បិចកលឈ្លានពានទឹកដីខ្មែររបស់ពួកគេដោយងាយដែរ។

ការអះអាងនេះ ធ្វើឡើងបន្ទាប់ពីថៃ បង្កើនការវាយប្រហារលើកម្ពុជាកាន់តែខ្លាំង និងចូលកាន់តែជ្រៅក្នុងទឹកដីខ្មែរ ក្នុងពេលដែលភាគីទាំងពីរកំពុងត្រៀមខ្លួនចរចាឱ្យមានបទឈប់បាញ់ដែរនោះ។

ទោះជាយ៉ាងណាក៏ដោយ មកទល់ពេលនេះ មិនទាន់មានអ្នកវិភាគតាមតក្កវិជ្ជាណាម្នាក់ហ៊ាននិយាយអះអាងដោយច្បាស់ប្រាកដថា ថៃវាយប្រហារខ្មែរបែបនេះមានចេតនាអ្វីពិតច្បាស់លាស់នោះទេ។តាមនិយមន័យក្នុងវិទ្យាសាស្ត្រនយោបាយ ពាក្យឈ្លានពាន (INVADE) គឺខុសច្បាប់អន្តរជាតិប៉ុន្តែត្រូវមានចេតនាច្បាស់លាស់មួយចំនួន។ ការចោទគ្នាទៅវិញទៅមកក៏កើតឡើងដោយសារតែការកាន់ជើងជាតិសាសន៍រៀងៗខ្លួនដែរ ឬក៏បរទេសខ្លះៗជួយខាងនេះ ឬខាងណោះ។ ខ្មែរចោទថា ថៃឈ្លានពាន គិតថារបបលោក ហ៊ុន សែន ជាអ្នករងគ្រោះ ឯថៃ ចោទថាខ្មែរបំពានអធិបតេយ្យជាតិគេ។

ថៃ គេថាគេបង្ក្រាបបណ្ដាញឆបោកពេញពិភពលោកដែលមានទីតាំងក្នុងប្រទេសកម្ពុជា និងជួយការពារដោយពួកមន្ត្រីមានអំណាចពុករលួយ។ សហគមន៍អន្តរជាតិបានត្រឹមតែអំពាវនាវសុំឲ្យបញ្ឈប់ការវាយប្រហារ ឬក៏ឈប់បាញ់គ្នា ចំណែកផលិតករគ្រឿងសព្វាវុធគិតតែពីលក់ឲ្យអតិថិជនណាដែលចង់ទិញប្រើ។

ប្រភពព័ត៌មានលោកខាងលិច

តទៅទំព័រទី១៩



# យោធាថៃ បន្តឈ្លានពានដោយទម្លាក់គ្រាប់បែកក្នុងទឹកដីខ្មែរតាមខេត្តប៉ែកខាងលិច និងខាងជើងនៃប្រទេសកម្ពុជា

ក្រសួងការពារជាតិកម្ពុជា ប្រកាសអាសន្នប្រាប់ពលរដ្ឋក្នុងខេត្តបាត់ដំបងឱ្យប្រុងប្រយ័ត្ន បន្ទាប់ពីយោធាថៃប្រើប្រាស់យន្តហោះចម្បាំងប្រភេទ T-50TH ទម្លាក់គ្រាប់បែកចំនួន ៥គ្រាប់ចូលជ្រៅទៅក្នុងសហគមន៍ជនស៊ីវិលនៅស្រុកបាណន់ ខេត្តបាត់ដំបង និង ៤គ្រាប់ទៀតនៅស្រុកស្រីស្នំ ខេត្តសៀមរាប នៅថ្ងៃពុធ។

នៅស្រុកបាណន់ យន្តហោះថៃទម្លាក់គ្រាប់បែកលើកទី១ ម៉ោង ១០ព្រឹក និងលើកទី២ នៅម៉ោងប្រមាណ ២រសៀល។ ចំណែកភូមិសាស្ត្រស្រុកស្រីស្នំ ខេត្តសៀមរាប ក៏ត្រូវយន្តហោះចម្បាំងប្រភេទ T-50TH ទម្លាក់គ្រាប់បែកចំនួន ៤គ្រាប់ចូលក្នុងភូមិដែលមានប្រជាជនកំពុងរស់នៅ ក្នុងថ្ងៃជាមួយគ្នាដែរនៅវេលាម៉ោង ១១ព្រឹក។

ស្រុកបាណន់ ខេត្តបាត់ដំបង នៅភាគពាយ័ព្យនៃប្រទេសកម្ពុជា និងមានចម្ងាយជិត ២០០គីឡូម៉ែត្រ (១៦៧គីឡូម៉ែត្រ) ពីស្រុកម៉ាឡៃ ដែលនៅជាប់ព្រំដែនថៃ និងមានចម្ងាយជិត ៧០គីឡូម៉ែត្រ (៦៧គីឡូម៉ែត្រ) ពីស្រុកសំឡូត ដែលនៅជាប់ព្រំដែនថៃ ដែរនោះ។ ចំណែកស្រុកស្រីស្នំ ខេត្តសៀមរាប ស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជាមានចម្ងាយ ៧០គីឡូម៉ែត្រពីស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដែលនៅជាប់ព្រំដែនថៃ និងមានចម្ងាយជិត ២០០គីឡូម៉ែត្រ (១៧៦គីឡូម៉ែត្រ) ពីច្រកទ្វារអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

ប្រភពដដែល អះអាងថា ចាប់ពីម៉ោង ១២ និង ១៥នាទី ដល់ម៉ោង ១២ និង ២៦នាទី យោធាថៃ បានប្រើប្រាស់យន្តហោះចម្បាំង T-50TH ទម្លាក់គ្រាប់បែកចង្កោមនៅភូមិសាស្ត្រឃុំស្លក្រាម ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ផងដែរ ហើយក្រៅពីទីតាំងទាំងនេះ ក៏ត្រូវរងការវាយប្រហារដោយអាវុធគ្រប់ប្រភេទពីកងទ័ពថៃ រួមទាំងយន្តហោះចម្បាំងថៃមទៀត។




ទីតាំងដែលយោធាថៃ ប្រើយន្តហោះចម្បាំង T-50 ទម្លាក់គ្រាប់បែក ៤គ្រាប់ក្នុងភូមិសាស្ត្រស្រុកបាណន់ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥។ (រូបភាពដោយ ថ្មីៗ)

ក្រសួងការពារជាតិប្រទេសកម្ពុជា អះអាងថា យោធាថៃ បានប្រើយន្តហោះចម្បាំងវាយប្រហារចូលទឹកដីប្រទេសកម្ពុជា កាន់តែជ្រៅក្នុងសង្គ្រាមចូលដល់ថ្ងៃទី១៧ គិតត្រឹមថ្ងៃទី២៤ ធ្នូ នេះ។

បណ្តាញទូរទស្សន៍ Thai PBS បានរាយការណ៍នៅថ្ងៃទី២៤ ធ្នូ នេះថា យន្តហោះចម្បាំងថៃ F-16 បានធ្វើការវាយប្រហារតាមអាកាសទៅលើឃ្លាំងអាវុធកម្ពុជានៅតំបន់ព្រំដែនដាច់ស្រយាលនៃខេត្តបាត់ដំបង នៅថ្ងៃទី២៤ ខែធ្នូនេះ ដែលបានបង្កការភ្ញាក់ផ្អើលដល់ប្រជាពលរដ្ឋក្នុងតំបន់យ៉ាងខ្លាំង។

ប្រជាពលរដ្ឋដែលរស់នៅក្នុងខេត្តបាត់ដំបង បានប្រាប់សារព័ត៌មាន The Cambodia Daily ក្នុងលក្ខខណ្ឌមិនបញ្ចេញឈ្មោះនៅថ្ងៃទី២៤ ធ្នូ នេះថា ថៃបានទម្លាក់គ្រាប់ប្រមាណជា ៧គ្រាប់ ចម្ងាយពីផ្ទះរបស់ពួកគាត់ប្រហែលជា ៥០០ម៉ែត្រ ស្ថិតក្នុងភូមិចែងក្តារ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង។

ប្រភពដដែល បញ្ជាក់ថា មុនទម្លាក់គ្រាប់ ពួកគេឃើញយន្តហោះថៃ T-50TH របស់ថៃ ហោះកាត់តំបន់របស់ពួកគាត់រស់នៅដែរ។

យោងតាមគេហទំព័រ Small Arms Survey បង្ហាញថា ប្រទេសថៃ មានយន្តហោះចម្បាំង៖

ប្រភេទ T-50TH ចំនួន ១៤គ្រឿង

យន្តហោះចម្បាំងប្រភេទ F-16 ចន្លោះពី ៤៧ ដល់ ៥៤គ្រឿង

យន្តហោះចម្បាំងម៉ាក Gripen ចន្លោះពី ៧ ដល់ ១១គ្រឿង

យន្តហោះចម្បាំងប្រភេទ Northrop F-5 Tiger II ចំនួន ១១គ្រឿង

និងយន្តហោះម៉ាក Dassault/ Dornier Alpha Jet A ចំនួន ១៨គ្រឿង ផងដែរ។

តម្លៃមួយគ្រឿងចន្លោះពី ២០-៣០ លានដុល្លារ។ យន្តហោះចម្បាំងធុនស្រាលប្រភេទ T-50TH Golden Eagle ជាយន្តហោះផលិតនៅប្រទេសកូរ៉េខាងត្បូង សហការជាមួយក្រុមហ៊ុនអាមេរិកាំង Lockheed Martin ដែលទ័ពអាកាសថៃ ប្រើក្នុងប្រតិបត្តិការតាមសមរភូមិគ្មានការគំរាមកំហែងដោយអាវុធធុនធ្ងន់។ រីឯយន្តហោះប្រភេទ Dassault/Dornier Alpha Jet A ផលិតដោយក្រុមហ៊ុនបារាំង និងអាល្លឺម៉ង់ ពីទសវត្ស ១៩៧០-១៩៨០ មួយគ្រឿងតម្លៃប្រមាណ ១២លានដុល្លារ ប៉ុន្តែបច្ចុប្បន្នតម្លៃប្រមាណតែ ១លានដុល្លារប៉ុណ្ណោះ។

ជុំវិញបញ្ហាទម្លាក់គ្រាប់បែកនេះ ប្រធានសភាពាណិជ្ជកម្មអាមេរិកាំងប្រចាំប្រទេសកម្ពុជា លោក ខេស៊ី បាណែត សរសេរលើគណនីហ្វេសប៊ុករបស់ខ្លួននៅថ្ងៃទី២៤ ធ្នូ នេះថា យោធាថៃ កំពុងទម្លាក់គ្រាប់បែកចូលជ្រៅក្នុងទឹកដីកម្ពុជា ចម្ងាយ ៩៨គីឡូម៉ែត្រក្បែរតំបន់ទេសចរណ៍ភ្នំសំពៅ ខេត្តបាត់ដំបង នៅថ្ងៃពុធនេះ។ ភាគីថៃ ប្រាប់សហគមន៍អន្តរជាតិថា គេសំដៅតែទៅលើទីតាំងប្រតិបត្តិការឆបោកតាមអន្តរបណ្តាញប៉ុណ្ណោះ។

រីឯក្រសួងមហាផ្ទៃកម្ពុជា វិញ បានបង្ហាញសេចក្តីរាយការណ៍នៅថ្ងៃទី២៤ ធ្នូ នេះដែរថា ទង្វើវាយប្រហារឈ្លានពានយ៉ាងកំរោលពីយោធាថៃ មកលើប្រទេសកម្ពុជា ក្នុងរយៈពេល ១៨ថ្ងៃមកនេះ បានធ្វើឱ្យពលរដ្ឋកម្ពុជា ជាង ៦សែននាក់ (៦០៨០៩៧នាក់) បានភៀសសឹកទៅរកទីសុវត្ថិភាព ដែលក្នុងចំណោមនោះ គឺមានស្ត្រីចំនួនជាង ៣សែននាក់ (៣១៨៧០៨នាក់) ខណៈកុមារក៏មានចំនួនជិត ២សែននាក់ផងដែរ (១៩១៩៥៧នាក់)៕

# Cambodia accuses Thailand of air strikes deep inside its territory

December 17, 2025
by The Cambodia Daily

The Cambodian Ministry of National Defence says Thai forces carried out a series of attacks inside Cambodian territory on December 15, including air strikes by fighter jets that penetrated deep into the country.

In a statement, the ministry said Thai military units launched 15 attacks over ten hours, beginning at 4.30 in the morning and continuing until 2.42 in the afternoon. It claimed that Thai F-16 aircraft dropped bombs as far as 70 kilometres inside Cambodia, near an area sheltering displaced civilians.

According to the ministry, the attacks targeted multiple locations along the border and beyond, including O'Smach, Prasat Khnar, Chub Angkunh,

Prasat Ta Moan Thom, Thmor Don, Prasat Ta Krabey, and the Preah Vihear temple area in Preah Vihear province. Shelling was also reported in Samraong town in Oddar Meanchey province, which officials described as a civilian-populated area.

Additional strikes were reported in Prey Chan village, Chouk Chey village, the Boeng Trakuon border crossing, and Preah Netr Preah district in Banteay Meanchey province, as well as Thmor Da commune in Veal Veng district of Pursat province.

The defence ministry said other areas remained calm but stressed that Cambodian forces were on high alert and continuing close monitoring. It said troops were prepared to defend Cambodia's territorial integrity on all fronts.




On the same day, Thai ground forces reportedly seized several GAM 102LR anti-tank missiles abandoned in the An Ses battlefield area, also known as Hill 500. The missiles have a range of about 10 kilometres and are designed to track armoured vehicles. They are produced by the Chinese company Poly Technologies and were recently displayed at an arms exhibition in Cairo earlier this month, with a reported unit price of 112,000 US dollars. Thai investigators are said to be examining how the weapons came into the hands of Cambodian forces so quickly.

The claims come as fighting between Cambodia and Thailand enters its ninth day, with the international community urging both sides to return to negotiations to end the conflict.

On December 15, Chinese foreign ministry spokesperson Guo Jiakun wrote

Please see /14



# អ្នកឃ្លាំមើលអះអាងថា ថៃមិនទាន់ដណ្ដើមកាន់កាប់ទឹកដីខ្មែរបាននៅឡើយទេរហូតមកដល់ពេលនេះ

អ្នកឃ្លាំមើលស្ថានការណ៍កម្ពុជា អះអាងថា សង្គ្រាមដែលថៃ ឈ្លានពានមកលើកម្ពុជា រយៈពេល ៥ថ្ងៃ កាលពីចុងខែកក្កដា និងបន្តធ្វើទុក្ខបុកម្នេញលើកម្ពុជា រហូតផ្ទុះសង្គ្រាមលើកទី២ នៅខែធ្នូ នេះ យោធាថៃ មិនទាន់អាចដណ្ដើមកាន់កាប់ទឹកដីខ្មែរបាននៅឡើយទេ ទោះថៃ ប្រើអាវុធគ្រប់ធុនព្យាយាមវាយសង្គ្រុបលើកម្ពុជា ក៏ដោយ។

អតីតមេធាវីសាលាក្ដីខ្មែរក្រហម លោក កង ឫទ្ធិគិរី សរសេរលើគណនីហ្វេសប៊ុករបស់ខ្លួននៅថ្ងៃទី១៧ ធ្នូនេះថា សង្គ្រាមដែលបានអូសបន្លាយចូលដល់ខែទី៦ នាពេលនេះ យោធាថៃ នៅតែមិនអាចដណ្ដើមបានទីតាំងណាមួយរបស់កម្ពុជា នៅឡើយ បើទោះបីជាថៃ បានប្រើកម្លាំងសរុបនៃកងយោធាថៃ ទាំងផ្នែកជើងទឹក និង ជើងអាកាសវាយប្រហារពេញទំហឹង



ក្រុមសង្គ្រោះរបស់ភាគីថៃ រុញសាកសពចូលឡានទៅខេត្តស៊ីសាកេត កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៥

ធ្លាក់ចូលជ្រៅជិត១០០គីឡូម៉ែត្រក្នុងទឹកដីកម្ពុជាក៏ ដោយ។

លោកថា ការប្រើកម្លាំងចម្រុះវាយពីចម្ងាយតាមអាកាស ជើងទឹក និងកាំភ្លើងធំបាញ់ផ្លោងដាក់ទីតាំងការពាររបស់កម្ពុជា គឺក្នុងបំណងបើកផ្លូវឲ្យកងទ័ពថ្មើរជើងវាយដណ្ដើមកាន់កាប់ទីតាំងការពារខ្លួនរបស់កម្ពុជាប៉ុណ្ណោះ ប៉ុន្តែថៃ នៅតែបរាជ័យដដែល។

អ្នកសង្កេតការណ៍កម្ពុជា រូបនេះ លើកឡើងថា ពេលនេះ ថៃបានប្ដូរពីសង្គ្រាមផ្ដេកបន្ទោរ មកជាសង្គ្រាមអង្កៀមវិញ ក្នុងបំណងធ្វើឱ្យសមត្ថភាពកងទ័ពកម្ពុជាចុះខ្សោយ ដោយបណ្ដាក់គ្នាវាយប្រហារមកលើទីតាំងការពាររបស់កម្ពុជា ទាំងយប់ ទាំងថ្ងៃ ក្នុងនោះ ថៃបានប្រើសព្វាវុធ និងអាយុជីវិតទាហានដល់ទៅ ១០ដង បើធៀបនឹងកម្ពុជា ដើម្បីឈ្នះសង្គ្រាមនេះ។

លោក កង ឫទ្ធិគិរី បញ្ជាក់ថា បើសង្គ្រាមនេះអូសបន្លាយពេលកាន់តែយូរ កម្ពុជាអាចចុះខ្សោយដូចផែនការរបស់យោធាថៃ ដូច្នេះកម្ពុជាត្រូវតែបង្កើនការវាយបកលើទាហានថៃ ឱ្យថយឆ្ងាយពីទីតាំងខ្លួនវិញ។ បន្ថែមពីនេះ កម្ពុជាក៏គួររកមធ្យោបាយទប់ស្កាត់

តទៅទំព័រទី១២




# យោធាថៃ បានសម្លាប់ជនស៊ីវិលកម្ពុជាកើន ១៧នាក់ ខណៈអ្នករងរបួសកើន ៧៧នាក់ និងជនភៀសសឹកកើនជាង ៤សែននាក់

ក្រសួងការពារជាតិកម្ពុជា អះអាងថា ការវាយប្រហារពីសំណាក់ភាគីថៃ នៅថ្ងៃទី១៧ ធ្នូ នេះ បានសម្លាប់ជនស៊ីវិលកើនឡើងដល់ ១៧នាក់ ក្នុងនោះគឺមានទារក ១នាក់ដែរ ខណៈពលរដ្ឋដែលរងរបួសបានកើនឡើងដល់ ៧៧នាក់។

អ្នកនាំពាក្យក្រសួងការពារជាតិ អ្នកស្រី ម៉ាលី សុជាតា បានចេញសេចក្តីប្រកាសព័ត៌មាននៅថ្ងៃទី១៧ ធ្នូ នេះ ថា គិតចាប់ពីម៉ោង ០៥ និង ០០នាទី ថ្ងៃទី១៦ ដល់ម៉ោង ០៨ និង ០០នាទី ព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ នេះ យោធាថៃ បានបើកការវាយប្រហារមកលើកម្ពុជា ចំនួន ១៧លើកក្នុងរយៈពេលជាង ១៦ម៉ោង។

ប្រភពដដែលអះអាងថារយៈពេល ១៦ម៉ោងនេះ យោធាថៃ បានវាយសម្រុកទៅលើភូមិសាស្ត្រចំនួន ១០ ទីតាំងក្នុងទឹកដីរបស់កម្ពុជា រួមមាន ភ្នំ ៣៣៣ ប្រាសាទតាក្របី តាថាវ ប្រាសាទតាមាន់ ថ្មដូន អូរក្លុកដំរី ភូមិជោគជ័យ ភូមិព្រៃចាន់ និងភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យផងដែរ។

ក្រសួងការពារជាតិ បញ្ជាក់ថា ថៃបានប្រើអាវុធ និងយុទ្ធោបករណ៍គ្រប់ប្រភេទសម្រាប់ការវាយប្រហារនេះ រួមមានយន្តហោះចម្បាំង F-16 រ៉ុក្កែត ឌី.ធី.អាយ-២ (DTI-2) នាវាចម្បាំង ដ្រូនពិឃាត កាំភ្លើងធំ ១០៥មិល្លីម៉ែត្រ និង ១៥៥មិល្លីម៉ែត្រ រថពាសដែក គ្រាប់បែកចង្កោម និងផ្សែងពុល ជាដើម រួមទាំងការដាក់ពង្រាយទាហានដ៏ច្រើនលើសលុបថែមទៀត។

ការអះអាងនេះ ធ្វើឡើងបន្ទាប់ពីសង្គ្រាមរវាងកម្ពុជា-ថៃ បានអូសបន្លាយចូលដល់ថ្ងៃទី១១ គិតត្រឹមថ្ងៃទី១៧ ធ្នូ នេះ។

ជុំវិញបញ្ហានេះ កាសែតបាងកកប៉ុស្ដិ៍ រាយការណ៍នៅថ្ងៃទី១៧ ធ្នូ នេះ ថា កាលពីថ្ងៃទី១៦ ខែធ្នូ គណៈរដ្ឋមន្ត្រីចាំផ្ទះរបស់ថៃ បានអនុម័តការបែងចែកថវិកាប្រមាណ ២,៤៤ពាន់លានបាត ឬប្រមាណ ៧៧,៦លានដុល្លារអាមេរិក

តទៅទំព័រទី២០


ជនភៀសសឹកកម្ពុជា ជម្លៀសទៅកាន់ទីសុវត្ថិភាពគេចចេញពីការវាយប្រហាររបស់យោធាថៃ តាមខេត្តជាប់ព្រំដែនកម្ពុជា-ថៃ

# ម៉ោង៧៖៣០នាទីព្រឹក ទាហានឈ្លានពានសៀម ប្រើយន្តហោះទម្លាក់គ្រាប់បែក នៅភូមិសាស្ត្រពង្រកងវ៉ា ក្រុងសិរីសោភ័ណ

(ព្រំដែន)៖ ម៉ោង៧៖៣០នាទីព្រឹក ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥នេះ ទាហានឈ្លានពានសៀម ប្រើយន្តហោះទម្លាកគ្រាប់បែក នៅភូមិសាស្ត្រពង្រកងវ៉ា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។



















តមកពីទំព័រទី ១០

# អ្នកឃ្លាំមើលអះអាងថា ថៃមិនទាន់

ការវាយប្រហារយន្តហោះចម្បាំងរបស់ថៃ ផងដែរ ដើម្បីចៀសវាងការខូចខាតប្រព័ន្ធប្រយុទ្ធរបស់ខ្លួន ទាំងជួរមុខ និងជួរក្រោយ។ លើសពីនេះ កម្ពុជាក៏គួរពិចារណាផែនការសង្គ្រាមរយៈពេលវែងដែរ ដើម្បីធានាដល់ការធ្វើសង្គ្រាមប្រឆាំងការឈ្លានពានពីសំណាក់កងទ័ពថៃ ដើម្បីអាចដំណើរការបានយូរអង្វែង និងទទួលបានជោគជ័យ។

ការអះអាងនេះ ធ្វើឡើងស្របពេលដែលសង្គ្រាមកម្ពុជា-ថៃ លើកទីពីរនេះបានអូសបន្លាយរយៈពេលអស់ ១១ថ្ងៃហើយ ខណៈស្ថានភាពសង្គ្រាមនៅតែតានតឹងដដែល។

កាលពីថ្ងៃទី១៦ ខែធ្នូ កាសែតថៃ The Nation បានស្រង់សម្ដីរដ្ឋមន្ត្រីក្រសួងការពារជាតិថៃ លោក ណាថាផន ណាក់ផានិត (Nattapon Nakpanich) ថាជម្លោះរវាងថៃ និងកម្ពុជា នឹងមិនអូសបន្លាយពេលយូរទេ ប៉ុន្តែថៃនឹងរឹតបន្តឹងការផ្គត់ផ្គង់ប្រេង និងសម្ភារៈយោធាកម្ពុជាវិញ។

ជាងនេះទៀត ក្នុងកិច្ចសម្ភាសន៍ជាមួយប្រព័ន្ធផ្សព្វផ្សាយ Thai PBS កាលពីថ្ងៃទី១៤ ខែធ្នូ អគ្គសេនាធិការកងទ័ពជើងគោកថៃ លោក ឆៃយ៉ាងព្រឹក ឌួងប្រាផាត (Chaiyapruek Duangprap) បានអះអាងថា គោលដៅចុងក្រោយរបស់កងទ័ពថៃ គឺធានាឱ្យបានថា កម្ពុជានឹងលែងបង្កការគំរាមកំហែងដល់សន្តិសុខជាតិរបស់ថៃ ក្នុងរយៈពេលយូរតទៅមុខទៀត។

លោក ឆៃយ៉ាងព្រឹក ឌួងប្រាផាត (Chaiyapruek Duangprapat) បញ្ជាក់ថា ដើម្បីសម្រេចគោលដៅនេះប្រទេសថៃ ចាំបាច់ត្រូវតែបន្សាបសមត្ថភាពយោធារបស់កម្ពុជា ឱ្យបានយូរអង្វែង ដូច្នេះថៃចាំបាច់ត្រូវតែកំណត់គោលដៅបំផ្លាញបរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធយោធារបស់កម្ពុជា ទាំងអស់។

សង្គ្រាមរវាងកម្ពុជាលើកទីពីរ បានចាប់ផ្តើមកាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ ដោយភាគីកម្ពុជា អះអាងថា ភាគីថៃជាអ្នកវាយប្រហារមុន ហើយបើគិតត្រឹមថ្ងៃទី១៧ ខែធ្នូនេះ គឺមានរយៈពេល ១១ថ្ងៃហើយ។

ជុំវិញសង្គ្រាមខ្មែរ-ថៃ នេះដែរ អតីតរដ្ឋមន្ត្រីក្រសួងព័ត៌មាន និងជាសមាជិកក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ លោក ខៀវ កាញារីទ្ធ បានសរសេរលើទំព័រហ្វេសប៊ុករបស់លោកកាលពីថ្ងៃទី១៥ ខែធ្នូ ថា ការវាយប្រហារចូលកាន់តែជ្រៅចូលក្នុងទឹកដីកម្ពុជា ក្នុងសង្គ្រាមនេះ មិនមែនជាការវាយដើម្បីវាតទីទឹកដីនោះទេ។

លោកថា បើថៃ មានបំណងវាតទីយកទឹកដី នោះទាហានថៃ ច្បាស់ជាប្រមូលផ្តុំកម្លាំងវាយផ្តាច់ចំណុចទាមទារមួយចំនួន មិនមែនវាយគ្រប់កន្លែងបែបនេះទេ។

លោកអះអាងថា ក្នុងពេលដែលថៃ ជិតបោះឆ្នោតខាងមុខនេះ យោធាថៃ នឹងធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីទាក់ទាញទំនុកចិត្តពលរដ្ឋថៃ ក្នុងនោះយុទ្ធសាស្ត្រចំពោះមុខដែលថៃ អាចនឹងប្រើ គឺមានបី។ បើយុទ្ធសាស្ត្រនេះអនុវត្តទៅទទួលបានជោគជ័យ វានឹងក្លាយជាយុទ្ធសាស្ត្រយូរអង្វែងរបស់ពួកគេផងដែរ។

លោកថា យុទ្ធសាស្ត្រទី១ គឺដើម្បីទាក់ទាញទំនុកចិត្តប្រជាជនថៃ ឱ្យជឿថា ថៃនៅតែជាបងធំក្នុងតំបន់។ ចំណែកយុទ្ធសាស្ត្រទី២ គឺថៃ ត្រូវសង្កត់សេដ្ឋកិច្ចកម្ពុជាឱ្យធ្លាក់ចុះតាមរយៈជនភៀសសឹក ដើម្បីឱ្យក្លាយជាបន្ទុករបស់រដ្ឋាភិបាល ខណៈយុទ្ធសាស្ត្រទី៣ គឺការវាយលុកកាន់តែជ្រៅចូលក្នុងដីកម្ពុជា ដើម្បីឱ្យពលរដ្ឋថៃ ជឿជាក់លើរាជរដ្ឋាភិបាល និងកងទ័ពរបស់ថៃ បន្តទៀត។

តទៅទំព័រទី១៤

ថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2025

**សេចក្តីជូនដំណឹងដល់អ្នកអាន និងអ្នកផ្សាយពាណិជ្ជកម្ម៖**

ក្នុងនាមជាសហស្ថាបនិក និងជាអ្នកបោះពុម្ពផ្សាយរបស់ Khmer Post USA ខ្ញុំសូមថ្លែងអំណរគុណចំពោះការគាំទ្ររបស់អ្នកសម្រាប់រយៈពេល ១៨ ឆ្នាំចុងក្រោយនេះ។ គិតចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ ២០២៦ – Khmer Post USA នឹងលែងបោះពុម្ពកាសែតរបស់យើងទៀតហើយ ប៉ុន្តែនឹងបន្តសេវាកម្មរបស់យើងនៅលើគេហទំព័រជាភាសាខ្មែរនិងភាសាអង់គ្លេសលើគេហទំព័រ www.khmerpostusa.com និង www.kh.khmerpostusa.com

យើងបានធ្វើការផ្លាស់ប្តូរនេះពេញមួយឆ្នាំ ២០២៥ ហើយយើងរីករាយក្នុងការចែករំលែក គេហទំព័ររបស់យើងដោយមានអ្នកអានជិត 100k ក្នុងមួយខែ។ នេះគ្រាន់តែជាការចាប់ផ្តើមនៃភាពជោគជ័យរបស់យើងក្នុងការប្រែក្លាយឧស្សាហកម្មព័ត៌មានរបស់យើង ពីការបោះពុម្ពទៅជា ឌីជីថល និងសម្របខ្លួនទៅនឹងពិភពលោកដែលមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយសង្គម។

សូមបន្តគាំទ្រការងាររបស់យើងដោយតាមដានពួកយើងនៅលើ www.khmerpostusa.com និងការផ្សាយពាណិជ្ជកម្មនៅលើគេហទំព័ររបស់យើងដែលភ្ជាប់ជាមួយសហគមន៍ខ្មែរ នៅរដ្ឋ ម៉ាសាឈូសេត និងនៅទីកន្លែងផ្សេងទៀត។

ជាថ្មីម្តងទៀត សូមអរគុណចំពោះការគាំទ្ររបស់លោកអ្នក។

ដោយក្តីគោរព
សុបិន អ៊ឹង
សហស្ថាបនិក និងការបោះពុម្ពផ្សាយ
Khmer Post USA, LLC
P.O. ប្រអប់ 8848
Lowell, Massachusetts 01853
www.khmerpostusa.com | www.kh.khmerpostusa.com

December 1, 2025

**Notice to Readers and Advertisers:**

As co-founder and publisher of Khmer Post USA, I like to thank you for your support for the last 18 years. Affective January 1, 2026 – Khmer Post USA will no longer printing our newspaper but will continue our service on the website in Khmer and English at www.khmerpostusa.com and www.kh.khmerpostusa.com



ស្ថាបនិកខ្មែរប៉ុស្តិ៍ សុបិន្ន អ៊ឹង

We have been working on this transition for the entire year of 2025 and we're pleased to share that our website reaches nearly 100k readers monthly. This is only the beginning of our success in transforming our news industry from print to digital and adapting to the fast changing world with social media.

Please continue to support our work by following us at www.khmerpostusa.com and advertising on our website which connects with the Cambodian communities in Massachusetts and beyond.

Again, thank you for your support.
Sincerely,
Soben Ung
Co-founder & Publisher
Khmer Post USA, LLC
P.O. Box 8848
Lowell, Massachusetts 01853
www.khmerpostusa.com | www.kh.khmerpostusa.com



# Healey-Driscoll Administration Launches New Youth Employment Pilot

Gateway Cities Youth Employment Network Pilot to Help State Develop Future Youth Employment Initiatives

Healey-Driscoll Administration launched the Youth Employment Gateway Cities Learning Community Pilot aimed at enhancing youth employment opportunities throughout the state. As part of the pilot, four MassHire Regional Workforce Boards, in partnership with Gateway Cities and employers, were awarded $75,000 to develop innovative approaches to youth engagement, employer partnerships, and career readiness.

The announcement was made by Secretary of Labor and Workforce Development Lauren Jones at the first quarterly learning community convening, which will serve as a forum for peer learning, joint problem-solving, and scaling effective youth-employment models.

"Every young person deserves the chance to explore their full potential and build a foundation for long-term success," said Governor Healey. "This pilot program will allow us to support their growth and empower the next generation of workers who will drive our economy forward."

"When we support youth employment, we're not just creating jobs, we're creating stronger communities," said Lieutenant Governor Kim Driscoll. "Early work experiences instill responsibility, spark curiosity and set young people on a path toward meaningful careers."







At the convening, Secretary Jones joined Lynn Mayor Jared Nicholson, Lynn Community Health Center CEO Brenda Rodriguez, and MassHire North Shore Workforce Board Executive Director Ed O'Sullivan for a fireside chat to discuss the collaboration needed to enhance youth employment opportunities, employer engagement strategies, and innovative next steps for municipalities and employers. The convenings are open to all MassHire Regional Workforce Boards and Gateway City leaders and seek to build a statewide learning community among Gateway cities, workforce boards, and employers committed to expanding equitable youth employment and work-based learning opportunities.

sting in our youth and young adults is an essential part of our state's strategy to develop pathways for our future talent and workforce. And it works, especially when we're focused on removing systemic barriers we know often hinder workforce entry," said Secretary of Labor and Workforce Development Lauren Jones. "Youth workforce development is more than just a job. It's about creating lifelong pathways to growth, equity, and opportunity. When young people engage in meaningful work, they gain confidence, skills, and networks that last a lifetime. I look forward to working with our partners on this pilot."

"The City of Lynn continues to see the tremendous impact that job placement has had on our youth," said Mayor Jared C. Nicholson. "We are grateful for this pilot launched by the Healey-Driscoll Administration and look forward to working with our partners. This initiative holds immense potential for our young residents as they develop their skills across sectors in our community."

Youth employment is a top workforce development priority for the Healey-Driscoll Administration. Since January 2023, more than 13,000 youth and young adults have been placed in a job or received job training through the Youthworks program, which places participants in jobs in industries such as education, health care, information technology, camp counselors, and arts and communications. Participants also received vital soft skills training, including leadership, project management, and customer service, and received workforce supports to reduce barriers to employment, including transportation.

# Sens. Markey, Warren, Rep. Trahan Statement on Escalating Violence Between Cambodia and Thailand

Washington (December 19, 2025) – Senator Edward J. Markey (D-Mass), Senator Elizabeth Warren (D-Mass.), and Representative Lori Trahan (MA-03) released the following statement today on the escalation of violence along the Cambodia-Thailand border. In recent weeks, long-standing tensions have erupted into renewed and intense clashes along the shared border, endangering innocent lives and threatening regional stability.



U.S Senator Elizabeth Warren, MA



U.S. Senator Edward Markey, MA

